នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Feb-2013, 14:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/**Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យប្រភេទនៃចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ អៀង សារី និង ខៀវ សំផន ពាក់ព័ន្ធនឹងការទទួលយកឯកសារមួយចំនួន**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

ក្រុមមេធាវីការពារក្តី:
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក សុន អរុណ
លោក Michiel PESTMAN

លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGES

# I. សេចក្តីផ្តើម

១- នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកធ្វើសវនាការលើឯកសារមួយទាក់ទងនឹងភាពអាចទទួលយកនៃឯកសារចំនួន ៤៨ ដែលបានស្នើឡើងដោយភាគីផ្សេងៗ ដូចបានចុះបញ្ជីដោយការិយាល័យសហព្រះរាជអាជ្ញា (កសព) នៅក្នុងឯកសារលេខ E223/2/1.1 និងឯកសារបន្ថែមចំនួន៩៤ ឯកសារ ទាក់ទងនឹងការជម្លៀសប្រជាជន (ដំណាក់កាលទី១ និងទី២) និងទួលពោធិ៍ជ្រៃ ដែលបានស្នើឡើងដោយដោយ កសព ក្នុងឯកសារលេខ E223/2/1.2, E223/2/1.3 និង E223/2/1.4[1] ។ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ មេធាវីការពារក្តី អៀង សារី បានធ្វើការជំទាស់ផ្ទាល់មាត់ទៅនឹងការទទួលយកឯកសារចំនួន៥៤ ដែលគាំទ្រដល់ដីកាដំណោះស្រាយ ទាក់ទងនឹងរចនាសម្ព័ន្ធកងព័ទកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាបានធ្វើការអះអាង ដោយផ្ទាល់មាត់ថាឯកសារចំនួន២៤ក្នុងចំណោមឯកសារ៥៤មិនបើកឲ្យមានការជជែកដេញដោលឡើយ ដោយហេតុថាឯកសារទាំងនោះភាគច្រើនត្រូវបានពិភាក្សារួចហើយកាលពីលើកមុននៅចំពោះមុខអង្គជំនុំជម្រះ ឬជាឯកសារច្រំដែល ដែលឯកសារទាំងនោះបានសម្រេចរួចហើយដែរដោយអង្គជំនុំជម្រះ[2]។ ប៉ុន្តែសហព្រះរាជអាជ្ញា និងភាគីដទៃទៀត មិនត្រូវបានអនុញ្ញាតឲ្យឆ្លើយតបទៅនឹងចម្លើយតបផ្ទាល់មាត់ទៅនឹងការជំទាស់របស់មេធាវីការពារក្តី អៀង សារី នៅពេលនោះឡើយ។

២- តាមរយៈសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនចេញនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យមេធាវីការពារក្តី អៀង សារី ដាក់សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួន ត្រឹមថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ទៅនឹងឯកសារដែលបានពិភាក្សានៅក្នុងសវនាការថ្ងៃទី២១ និង២២ ខែមករា ឆ្នាំ២០១៣។ មេធាវីការពារក្តី អៀង សារី បានអនុវត្តតាមការបង្គាប់នេះដោយបានដាក់ "សេចក្តីជំទាស់ទៅនឹងការទទួលយកឯកសារមួយចំនួន"[3] (ចាប់ពីនេះតទៅហៅថា "សេចក្តីជំទាស់របស់ អៀង សារី")។ អង្គជំនុំជម្រះសាលាដំបូងក៏បានស្នើឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា ដាក់សេចក្តីជំទាស់របស់ខ្លួនផងដែរ បើសិនជាមាន ត្រឹមថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣។ មកដល់កាលបរិច្ឆេទនេះ មេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីជំទាស់របស់ខ្លួនដែលមាន

[1] **E1/161.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២១ មករា ២០១៣។

[2] **E1/162.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២២ មករា ២០១៣, ត្រង់ 13:43 និងចាប់ពី 13:51 – 14:09។

[3] **E223/3/2**, ការជំទាស់របស់ អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួន, ២៣ មករា ២០១៣ និងតារាងភ្ជាប់លេខៈ **E223/2/2.1**, **E223/2/2.2**, **E223/2/2.3**, **E223/2/2.4** និង **E223/2/2.5**។

ចំណងជើងថា "*Exceptions d'irrecevabilité portent sur les documents relatifs aux déplacements de population et au site de Tuol Po Chrey (avec annexes)*"[4] (ចាប់ពីនេះតទៅហៅថា "សេចក្តីជំទាស់របស់ ខៀវ សំផន") និង នួន ជា បានដាក់ចម្លើយតបរបស់គាត់ទៅនឹងការជំទាស់របស់ កសព ទៅនឹងឯកសាររបស់មេធាវីការពារក្តី លេខ E131/1/13.11[5]។ នួន ជា មិនជំទាស់នឹងឯកសារណាមួយក្នុងចំណោមឯកសារដែលបានពិភាក្សាគ្នានៅក្នុងសវនាការ ថ្ងៃទី២១ និងទី២២ ខែមករា ឆ្នាំ២០១៣ទេ។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីទាំងអស់ឆ្លើយតបត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣។

## II. **អំណះអំណាង**

៣- ដូចដែលសហព្រះរាជអាជ្ញាធ្លាប់ធ្វើការឆ្លើយតបនាពេលកន្លងមក ទៅនឹងការជំទាស់មួយចំនួនរួចហើយទាក់ទងនឹងឯកសារក្នុងជំពូក ឬប្រភេទដូចគ្នានេះ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាធ្វើការបង្រួមបញ្ចូលគ្នា តាមរយៈសេចក្តីយោងនូវអំណះអំណាងទាំងនោះដែលបានដាក់ជូនទាំងដោយផ្ទាល់មាត់ ក្នុងសវនាការស្តីពីភាពអាចទទួលយកបាននៃឯកសារនៅថ្ងៃទី១៦-១៩ ខែមករា[6], ១៦ ខែកុម្ភៈ[7], ១២-១៥ ខែមីនា ២០១២[8] និងនៅថ្ងៃទី២១ និង២២ ខែមករា ឆ្នាំ២០១៣[9] ព្រមទាំងតាមរយៈសារណា

---

[4] **E223/2/4**, សេចក្តីជំទាស់របស់ ខៀវ សំផន ទៅលើឯកសារពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងទីតាំងទួលពោធិ៍ជ្រៃ *(ជាមួយឧបសម្ព័ន្ធ)*, ៨ កុម្ភៈ ២០១៣, ជាមួយឧបសម្ព័ន្ធ **E223/2/4.1**, **E223/2/4.2**, **E223/2/4.3**, **E223/2/4**។ មិនទាន់មានជាភាសាអង់គ្លេសនៅឡើយនៅពេលមានចម្លើយតបរួមនេះ។

[5] **E223/2/3**, ចម្លើយតបរបស់ នួន ជា ទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញាចំពោះឯកសាររបស់មេធាវីការពារក្តី, ៨ កុម្ភៈ ២០១៣ ដែលពិភាក្សាលើឯកសារតែមួយគត់ គឺឯកសារ **E131/1/13.11**។

[6] **E1/27.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៦ មករា ២០១២ (បញ្ហាក័ស្តុតាងទូទៅ ភាពអាចទទួលយកបាននៃឯកសារដែលបានលើកយោងក្នុងកំណត់សំគាល់ជើងទំព័រនៃដីកាដំណោះស្រាយ ទាក់ទងនឹងប្រវត្តិសាស្ត្រ)។ **E1/28.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៧ មករា ២០១២ (ភាពអាចទទួលយកបាននៃឯកសារដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ១ និង២ របស់ កសព តាមឯកសារលេខ E109/4)។ **E1/29.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៨ មករា ២០១២ (ភាពអាចទទួលយកបាននៃឯកសារដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ២, ៣ និង៤ របស់ កសព តាមឯកសារលេខ E109/4)។ **E1/30.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៩ មករា ២០១២ (ភាពអាចទទួលយកបាននៃឯកសារដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ៤ និង៥ របស់ កសព តាមឯកសារលេខ E109/4)។

[7] **E1/45.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៦ កុម្ភៈ ២០១២ (ភាពអាចទទួលយកបាននៃឯកសារដែលបានលើកយោងក្នុងកំណត់សំគាល់ជើងទំព័រនៃដីកាដំណោះស្រាយ ទាក់ទងនឹងរចនាសម្ព័ន្ធ និងការប្រាស្រ័យទំនាក់ទំនង)។

[8] **E1/46.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១២ មីនា ២០១២, **E1/47.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៣ មីនា ២០១២ **E1/48.1** ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង ១៤ មិនា ២០១២ និង **E1/49.1** ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៥ មីនា ២០១២ (ភាពអាចទទួលយកបាននៃឯកសាររបស់ កសព ក្នុងឯកសារលេខ A6-A11 និង A14-A20 តាមឯកសារលេខ E109/4 និងឯកសាររបស់ភាគីផ្សេងៗដទៃទៀត)។

ជាលាយល័ក្ខណ៍អក្សរកន្លងមក[10]។ សហព្រះរាជអាជ្ញាយោងជាពិសេសទៅរកទឡ្ហីករណ៍ ដែលបានធ្វើឡើងដោយផ្ទាល់មាត់ និងយ៉ាងលម្អិតកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ របស់ខ្លួន ពាក់ព័ន្ធទៅនឹងឯកសារដែលបានចាត់ចូលក្នុងប្រភេទជា ការប្រាស្រ័យទំនាក់ទំនងជាអន្តរជាតិ របាយការណ៍សារព័ត៌មានអន្តរជាតិ របាការណ៍ស្រុកត្រាំកក់ និងខ្សែវីឌីអូ[11]។ សហព្រះរាជអាជ្ញាក៏យោងទៅរកសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដែលបានធ្វើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ផងដែរ ពាក់ព័ន្ធនឹងឯកសារចំនួន២៤ដែលសហព្រះរាជអាជ្ញាពិចារណាថាមិនគួរបើកឲ្យមានការពិភាក្សាដេញដោល[12]។

៤- តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាថា ភាគច្រើននៃសេចក្តីជំទាស់ដែលក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន បានលើក សុទ្ធតែត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយតាមសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះ។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលយកក្នុងឆ្នាំ២០១២ ឯកសារទាំងអស់ដែលបានស្នើឡើងដោយភាគីថា *មានសេចក្តីបញ្ជាក់ដំបូង* ថាមានជាប់ពាក់ព័ន្ធ មានភាពជឿជាក់បាន និងមានយថាភូត(សូមមើលផ្នែក ក ខាងក្រោម) លើកលែងតែឯកសារពីរបីប៉ុណ្ណោះ។ សេចក្តីជំទាស់ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន ភាគច្រើនទាក់ទងទៅនឹងឯកសារក្នុងជំពូក ឬប្រភេទដូចគ្នានឹងឯកសារដែលបានពិចារណាដោយអង្គជំនុំជម្រះថាបានដាក់នៅចំពោះមុខខ្លួន។ ដើម្បីឲ្យមានភាពស៊ីសង្វាក់គ្នានឹងយុត្តិសាស្ត្ររបស់ខ្លួនផ្ទាល់ អង្គជំនុំជម្រះសាលាដំបូងគួរតែទទួលយកឯកសារបន្ថែមដែលមានចរិកលក្ខណៈដូចគ្នានេះ ពីព្រោះឯកសារទាំងឡាយណាដែលគេគិតថា អាចទទួលយកបាន(សូមមើលផ្នែក ខ)។ ជាចុងក្រោយ សហព្រះរាជអាជ្ញានឹងលើកសេចក្តីជំទាស់មួយចំនួនផ្សេងទៀត(សូមមើលផ្នែក គ)។

---

[9] **E1/161.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង ២១ មករា ២០១៣ និង **E1/162.1** ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង ២១ មករា ២០១២ សវនាការពេលរសៀល។

[10] សូមមើល **E114/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាន នូវប្រភេទឯកសារមួយចំនួន", ១៦ កញ្ញា ២០១១។ **E131/19,** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នឹងបញ្ជីឯកសារសម្រាប់សវនាការវគ្គដំបូង, ២ ធ្នូ ២០១១។ **E158**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងសូចនាករអំពីការជឿទុកចិត្ត ចំពោះឯកសារចំនួន៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង, ២៣ ធ្នូ ២០១១។ **E168/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង *"សំណើសុំឲ្យមានការដាក់បង្ហាញឯកសារពីសម័យនោះជាសំណៅដើមនៅក្នុងសវនាការ"* របស់ ខៀវ សំផន, ២០ កុម្ភៈ ២០១២។

[11] **E1/161.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២១ មករា ២០១៣, ត្រង់ 11:17 - 11:45 និង 14:00 - 14:18។

[12] **E1/162.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២២ មករា ២០១៣, ត្រង់ 13:43 និងពី 13:51 – 14:09។

(ក) <u>សេចក្តីជំទាស់របស់មេធាវីការពារក្តី មានភាពផ្ទុយគ្នាពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង</u>

៥- ទីមួយ៖ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានធ្វើសេចក្តីសម្រេចផ្ទាល់មាត់អំពីបទដ្ឋានសម្រាប់ការទទួលយកភ័ស្តុតាង[13] និងក្រោយមកបានបញ្ជាក់ពីសេចក្តីសម្រេចតាមអនុស្សរណៈចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២[14]។ អង្គជំនុំជម្រះបានសម្រេចថា ឯកសារដើម និងព័ត៌មានដែលពាក់ព័ន្ធស្តីពីយថាភូត ប្រភពដើមរបស់ឯកសារ និងខ្សែសង្វាក់នៃការគ្រប់គ្រង មិនមែនជាលក្ខខណ្ឌតម្រូវទេសម្រាប់គោលបំណងនៃការទទួលយកជាភ័ស្តុតាងនោះ ដោយថ្លែងយ៉ាងដូច្នេះថា៖

*ឯកសារដែលអាចទទួលយកបាន តម្រូវឱ្យឯកសារនោះបំពេញបាននូវសេចក្តីបញ្ជាក់ដំបូងនៃភាពពាក់ព័ន្ធ ភាពជឿជាក់បាន និងយថាភូត។ ឧទាហរណ៍ ប្រសិនបើឯកសារមួយមិនបានបង្ហាញថាក្លែងក្លាយ ឬជាឯកសារមិនតំណាងឱ្យឯកសារដើមក្តី ឯកសារនេះនឹងត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ"[15] ។*

៦- សហព្រះរាជអាជ្ញាសន្និដ្ឋានថា ក្រុមមេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថា ឯកសារណាមួយនៃឯកសារដែលពួកគេបានជំទាស់ទាំងនេះ ជាឯកសារក្លែងក្លាយ ឬឯកសារមិនតំណាងឱ្យឯកសារដើមឡើយ។

៧- ទីពីរ៖ ភាគច្រើននៃសេចក្តីជំទាស់ដែលបានដាក់ដោយក្រុមមេធាវីការពារក្តី ទាំងដោយផ្ទាល់មាត់ និងជាលាយល័ក្ខណ៍អក្សរ គឺមានលក្ខណៈទូទៅ ដែលមិនមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ទេ និងមិនបានកំណត់អំពីចរិកលក្ខណៈ ដែលអាចនាំឱ្យឯកសារទាំងនោះមិនអាចឱ្យជឿជាក់បាន ឬមិនអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះឡើយ។ ដូចអង្គជំនុំជម្រះបានថ្លែងក្នុងកថាខណ្ឌទី២៣ នៃសេចក្តីសម្រេចរបស់ខ្លួន តាមឯកសារ E185 ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ដូច្នេះថា៖

---

[13] **E1/34.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២៦ មករា ២០១២, ត្រង់ 15:05-15:15។

[14] **E162**, ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158, ៣១ មករា ២០១២ ("សេចក្តីសម្រេចលើភាពអាចទទួលយកបាន")។

[15] **E162**, កថាខណ្ឌទី២។

*សេចក្តីជំទាស់ត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ ហើយ [...] នៅពេលមិនមានការបញ្ជាក់ឲ្យបានច្បាស់លាស់គ្រប់គ្រាន់ មានតែការជំទាស់ដែលចោទប្រកាន់ថាឯកសារណាមួយខ្វះនូវភាពជឿជាក់បាន ឬភាពជាប់ពាក់ព័ន្ធជាក់ច្បាស់ប៉ុណ្ណោះ ដែលនឹងត្រូវអង្គជំនុំជម្រះពិនិត្យពិចារណា*[16] ។

៨- មេធាវីការពារក្តី អៀង សារី ពិតជាបានភ្ជាប់នូវតារាងមួយចំនួនទៅនឹងសំណើសុំរបស់ខ្លួន ដែលសេចក្តីជំទាស់ដូចគ្នាហាក់បីដូចជាបានចម្លងចេញ និងដាក់បញ្ចូលសម្រាប់ឯកសារនិមួយៗទៅតាមប្រភេទ ឬជំពូកឯកសារជាក់លាក់។ ទោះបីជាសេចក្តីជំទាស់ទាំងនោះហាក់បីដូចជាមានលក្ខណៈច្បាស់លាស់បើមើលមួយក្រឡេកភ្នែកដំបូងក៏ដោយ ក៏ភាពច្រំដែលមានលក្ខណៈជាប្រព័ន្ធនៃសេចក្តីជំទាស់ទាំនោះបង្ហាញឲ្យឃើញថា សេចក្តីជំទាស់ទាំងនោះមិនច្បាស់លាស់ឡើយ។ ឧទាហរណ៍ក្នុងឧបសម្ព័ន្ធ E223/2/2.1 និង E223/2/2.5 មេធាវីការពារក្តី អៀង សារី បានធ្វើអំណះអំណាងដូចគ្នាច្រំដែលៗចំនួន២១លើក[17] ថាត្រូវបានបដិសេធយ៉ាងច្បាស់ដោយអង្គជំនុំជម្រះសាលាដំបូងដោយសារកង្វះនូវភាពជាក់លាក់ តាមសេចក្តីសម្រេចរបស់ខ្លួនលេខ E185[18]។ អំណះអំណាងមានដូចតទៅនេះ៖ *"យោងតាមវិធាន៨៧(៣) មេធាវីការពារក្តីជំទាស់ទៅនឹងការទទួលយកឯកសារនេះ វៀរលែងតែ កសព អាចបង្ហាញឲ្យបានគ្រប់គ្រាន់នៃយថាភូត ភាពជឿជាក់បាន និងភាពជាប់ពាក់ព័ន្ធនៃឯកសារនេះ តាមរយៈការបង្ហាញឲ្យឃើញពីបុគ្គលណាជាអ្នកទទួលខុសត្រូវចំពោះខ្លឹមសារនៃឯកសារនេះ"*។ មេធាវីការពារក្តីខកខានមិនបានមិនបានយល់ថា តេស្តសម្រាប់ការទទួលយក គឺ *សេចក្តីបញ្ជាក់ដំបូង*នៃការបំពេញទៅតាមបទដ្ឋាននៃភាពពាក់ព័ន្ធ ភាពជឿជាក់បាន និងយថាភូត។

៩- សេចក្តីជំទាស់ទាំង៧ របស់ អៀង សារី ខាងក្រោមនេះ ត្រូវបានបដិសេធស្រដៀងគ្នាដែរចំពោះខ្លឹមសាររបស់វាដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីពីមុនដែលមានសំអាងហេតុ៖

(ក) សេចក្តីជំទាស់ដំបូងគឺថា *"អៀង សារី មិនត្រូវបានផ្តល់ ឱកាសឲ្យដេញដោលលើម្ចាស់ឯកសារនេះទេ។ ហេតុនេះ ឯកសារនេះគួរតែសម្រេចថាមិនអាចទទួលយកបាន ដោយ*

---

[16] **E185**, សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញានិងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១, ៩ មេសា ២០១២, កថាខណ្ឌទី២៣។

[17] **E223/2/2.1**: ឯកសារដែលមានលេខ២-១៤ និង១៦; **E223/2/2.5**: ឯកសារ១-៣, ១៤, ១៨, ២០ និង៣៧។

[18] **E185**, កថាខណ្ឌទី២៣ យោងសេចក្តីជំទាស់របស់មេធាវីការពារក្តីដែលបាននិយាយក្នុងកថាខណ្ឌទី១៥(ix) *("វិធាន៨៧(៣) តម្រូវឲ្យសហព្រះរាជអាជ្ញាបង្ហាញឲ្យបានគ្រប់គ្រាន់នូវយថាភូត ភាពជឿជាក់បាន និងភាពជាប់ពាក់ព័ន្ធនៃឯកសារទាំងអស់")*។

*អនុលោមតាមវិធាន៨៧(៣)(ឃ)* ឬសម្រេចស្រដៀងគ្នានេះថា *"ម្ចាស់ឯកសារនេះមិនត្រូវបានកំណត់ពេលឱ្យមកផ្តល់សក្ខីកម្មនាពេលបច្ចុប្បន្ននេះក្នុងសំណុំរឿង ០០២/១ ទេ។ ដោយសារលោក អៀង សារី មិនត្រូវបានផ្តល់នូវសិទ្ធិដាច់មុខតាមវិធាន៨៤(១) ដើម្បីដេញដោលម្ចាស់អត្ថបទនេះ ឯកសារនេះក៏មិនអាចទទួលយកបានដែរអនុលោមតាមវិធាន៨៧(៣)(ឃ)"*។ សេចក្តីជំទាស់នេះត្រូវបាន អៀង សារី ធ្វើឡើងវិញចំនួន៨៥ដងក្នុងចំណោមឯកសារបន្ថែមចំនួន៨៨ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ទាក់ទងនឹងការជម្លៀសប្រជាជនលើកទីមួយ[19]។ វាគ្មានតម្លៃអ្វីសោះដែលការជំទាស់នេះមិនត្រូវបានលើកទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ុន្តែបែរជាទាក់ទងទៅនឹងប្រភេទឯកសារ ដូចជា៖ ការប្រាស្រ័យទំនាក់ទំនងអន្តរជាតិ របាយការណ៍សារព័ត៌មានអន្តរជាតិ កំណត់ហេតុស្រុកត្រាំកក់។ ការជំទាស់នេះត្រូវបានលើកច្រំដែលជាច្រើនលើកទៀតនៅក្នុងឧបសម្ព័ន្ធដទៃទៀត[20]។ សេចក្តីជំទាស់ទាំងនេះ មានភាពផ្ទុយគ្នាទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលថា *"គ្មានលក្ខខណ្ឌតម្រូវខាងផ្នែកនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ឱ្យកោះហៅសាក្សីដែលមានចំណេះដឹងផ្ទាល់ខ្លួន ចំពោះយថាភូតឯកសារដែលមាននៅក្នុងសំណុំរឿងឡើយ"* (E185, កថាខណ្ឌទី 21, 7)។ លើសពីនេះ ឯកសារទាំងនេះដែលមេធាវីការពារក្តី អៀង សារី បានជំទាស់នោះ មិនជាប់ពាក់ព័ន្ធនឹងអំពើនិងការប្រព្រឹត្តរបស់ជនជាប់ចោទទេ ប៉ុន្តែជាការជម្លៀសទីក្រុងភ្នំពេញ ឬជាការដាក់គោលដៅចំពោះខ្មាំងដែលគេហៅថា "មន្ត្រីសាធារណរដ្ឋខ្មែរ" "ប្រជាជនថ្មី" ឬ "អ្នកដែលគេជម្លៀស" ក្នុងស្រុកត្រាំកក់។

(ខ) ការជំទាស់ទីពីរដែលបានលើកឡើងដោយ អៀង សារី គឺមានដូចតទៅ៖ *"ប្រសិនបើឯកសារនេះត្រូវបានទទួលយក មេធាវីការពារក្តីលើកឡើងថា ឯកសារនេះមានទម្ងន់មានកម្រិតនោះ ប្រសិនបើមាន ខ្លឹមសារនៃឯកសារនេះអាចត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ឬគាំទ្រតាមរយៈសូចនាឯករាជ្យមួយ"* ឬ *"ប្រសិនបើឯកសារនេះត្រូវបានទទួលយក ត្រូវគេផ្តល់ទម្ងន់ឱ្យតិចតួចអញ្ចឹង ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចពីមុន នោះ*

[19] **E223/2/2.1**: ឯកសារដែលមានលេខរៀង២-៣៥, ៣៦, ៤០-៨៧។

[20] **E223/2/2.2**, ឯកសារ១; **E223/2/2.3**, ឯកសារ១-៣, **E223/2/2.4**, ឯកសារ៤ និង៦-៧; **E223/2/2.5**, ឯកសារចំនួន៣០ ដែលមានលេខដូចតទៅនេះ ៖ ១-៣, ៥-9, ១៤-៣៣, ៣៥-៣៦។

*"ឯកសារច្បាប់ដើម គឺជាវិធីមួយល្អក្នុងការបង្ហាញភស្តុតាង និងត្រូវបានទទួលស្គាល់ថា មានទម្ងន់ច្រើនជាងឯកសារថតចម្លង" សូមអានឯកសារលេខE185,កថាខណ្ឌទី២១"*[21] ។ របៀបនេះមិនមែនជាការជំទាស់នោះទេ ហើយដូច្នេះវាមិនពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីភាពស្របគ្នានៃឯកសារ ជាមួយនឹងតេស្តស្តីពីភាពអាចទទួលយកបាននោះឡើយ។ ភាគីនានានឹងមានឱកាសនៅពេលក្រោយ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ពួកគេ ដើម្បីធ្វើការពិភាក្សាអំពីតម្លៃជាភស្តុតាងរបស់ឯកសារ។ ដូចដែល អង្គជំនុំជម្រះសាលាដំបូងបានរំឭកដូច្នោះដែរថា (ឯកសារលេខ E185/1 *"តម្លៃ និងទម្ងន់នៃភស្តុតាងដែលទទួលស្គាល់ជាភស្តុតាងទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នឹងត្រូវបានសម្រេចដោយអង្គជំនុំជម្រះនៅពេលបញ្ចប់សវនាការដេញដោលលើភស្តុតាង ក្នុងសំណុំរឿង ០០២/០១ នៅពេលពិចារណាចេញសាលក្រម"*។

(គ) ទីបី៖ មេធាវីការពារក្តី អៀង សារី បាននិយាយច្រំដែលយ៉ាងហោចណាស់ចំនួន ៤៦ ដង[22] បន្ទាប់ពីការជំទាស់ដែលទាក់ទងនឹងការប្រាស្រ័យទាក់ទងជាអន្តរជាតិ របាយការណ៍សារព័ត៌មានអន្តរជាតិ ឬ របាយការណ៍វិភាគ៖ *"មេធាវីការពារក្តីទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា "សម្ភារៈមួយចំនួន ដូចជា របាយការណ៍ការវិភាគ សៀវភៅ ភាពយន្តឯកសារ និងអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ អាចមានការពាក់ព័ន្ធ ហើយនឹងត្រូវរាប់ចូលជាប្រភេទនៃឯកសារមួយផងដែរ" (ឯកសារ E185, កថាខណ្ឌ ២១(៥)។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីអះអាងថា អត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ មិនអាចទទួលយកថាមានលក្ខណៈត្រឹមត្រូវ ឬសត្យានុម័តឡើយ ជាពិសេសនៅ ពេលដែលអ្នកកាសែត អាចត្រូវបានរដ្ឋាភិបាលផ្តល់ឱ្យបង្ហាញនូវរបាយការណ៍ជាក់លាក់មួយអំពីព្រឹត្តិការណ៍នានា ឬឱ្យបង្កើតនូវព័ត៌មានមិនពិត។ ស្រដៀងគ្នានេះ វាស្ទើរតែមិនអាចគេត្តបានឡើយអំពីភាពត្រឹមត្រូវនៃអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ ដោយគ្មាន ក្នុងកម្រិតអប្បបរមា ការបង្ហាញភស្តុតាង*

---

[21] សេចក្តីជំទាស់នេះគឺមានលក្ខណៈច្រំដែលចំនួន ៨៣(ប៉ែតសិបបី)ដង នៅក្នុង **E223/2/2.1**, នៅក្នុងការជំទាស់ដែលបានបង្កើតឡើងប្រឆាំងនឹងឯកសារដែលមានលំដាប់ ២-៣៥ និង ៤០-៨៧។

[22] **E223/2/2.1**: សេចក្តីជំទាស់នេះគឺមានលក្ខណៈច្រំដែល ចំពោះ ២០(ម្ភៃ)ឯកសារ, ដែលមានលេខ ១៥, ១៧-៣៥។ **E223/2/2.2**, ឯកសារ ១។ **E223/2/2.4**, រួមទាំងឯកសារ ៤ និង ៩។ **E223/2/2.5**, ២៣(ម្ភៃបី)ឯកសារ ដែលមានចុះជាបញ្ជីលេខ ៥-៩, ១៥-១៧, ១៩, ២១-៣៣ និង ៣៥។

*ពីអ្នកនិពន្ធនោះ។ វាមិនអាចផ្ទៀងផ្ទាត់បានឡើយ អំពីភាពគួរឲ្យជឿជាក់បាននៃរបាយការណ៍ដែលមាននៅក្នុងអត្ថបទនោះ។ អត្ថបទនេះ មានព័ត៌មាន និងសេចក្ដីសន្និដ្ឋានដែលមិនបានផ្អែកទៅលើការអង្កេតផ្ទាល់អំពីព្រឹត្តិការណ៍ទាំងនោះឡើយ"។*

នៅក្នុងការជំទាស់ដដែលនេះ មេធាវីការពារក្ដីអះអាងថាបានដឹងពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនបដិសេធប្រភេទឯកសារមួយចំនួន ដូចជាៈ កាលណាឯកសារទាំងនោះមានជាប់ទាក់ទងគ្នា ហើយប៉ុនប៉ងធ្វើការជំទាស់ទៅនឹងរបាយការណ៍សារព័ត៌មានទាំងអស់ (ប្រភេទឯកសារមួយបែបនោះ) និងធ្វើការប្រឆាំងទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះ ដោយគិតស្មានអំពីអង្គហេតុដែលគ្មានខ្លឹមសារដែល *"អ្នកកាសែតខ្លះ <u>អាច</u>ត្រូវបានរដ្ឋាភិបាលជួល"*[23]។ ការយល់ឃើញផ្សេងទៀតដែលបានលើកឡើងដោយមេធាវីការពារក្ដីនៅក្នុងការជំទាស់ដដែលនេះ ជាក់ស្ដែង ទាក់ទងទៅនឹងតម្លៃជាភស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកជាភស្តុតាងបែបដូច្នេះ។ ជាងនេះទៀត មេធាវីការពារក្ដីខកខានមិនបានលើកឡើងទេថា ភាគច្រើននៃអត្ថបទកាសែត ឬរបាយការណ៍ ដែលពួកគេបានជំទាស់នោះ ជាក់ស្ដែង គឺមានផ្ទុកនូវព័ត៌មាន ឬសេចក្ដីសន្និដ្ឋានផ្សេងៗ ដែលមានមូលដ្ឋាននៅលើការសង្កេតដោយផ្ទាល់ទៅលើព្រឹត្តិការណ៍នានា។ ជាឧទាហរណ៍ ឯកសារលេខ D108/28.33 គឺជារបាយការណ៍ប្រចាំឆ្នាំមួយរបស់ ICRC ស្ដីពីប្រទេសកម្ពុជា នៅឆ្នាំ១៩៧៥, ១៩៧៨ និង ១៩៧៩ៈ ដែលមានការទាក់ទងទៅនឹងការជម្លៀសទីក្រុងភ្នំពេញ ការពិពណ៌នារបស់ ICRC គឺមានមូលដ្ឋាននៅលើការសង្កេតដោយផ្ទាល់ទៅលើព្រឹត្តិការណ៍នានា ដោយរួមទាំង ការជម្លៀសនៅថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ឲ្យចេញពីមន្ទីរពេទ្យ និងពីតំបន់សុវត្ថិភាពដែលគេបានបង្កើតឡើង នៅ "សណ្ឋាគារឡឺភ្នំ"ផង។ អង្គហេតុនេះត្រូវបានគាំទ្រដោយសាក្សី Al Rockoff នៅពេលសវនាការកាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣[24] និងដោយសាក្សី TCW-536 នៅក្នុងសៀវភៅរបស់គាត់ ឯកសារលេខ E243.1[25]។ ឯកសារដទៃទៀត ដែលបានសរសេរនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏បានពឹងផ្អែក

[23] សង្កត់ន័យបន្ថែមដោយ <u>គូសបន្ទាត់ពីក្រោម</u>។

[24] **E1/165.1**, ប្រតិចារឹកសវនាការ, ២៨ មករា ២០១៣, ត្រង់ម៉ោង ០៩:៥៧។

[25] **E243.1**, សៀវភៅបោះពុម្ពផ្សាយនៅថ្ងៃទី ២៣ តុលា ១៩៧៦, ត្រង់ បារាំង ERN 00862144, អង់គ្លេស ERN 00862031, ខ្មែរ ERN 00862293។

ទៅលើការសង្កេតដោយផ្ទាល់ទៅលើព្រឹត្តិការណ៍នានាផងដែរ ដូចជា ឯកសារលេខ D153.13 (របាយការណ៍របស់ USAID ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ ១៩៧៥)[26] ឬ ឯកសារលេខ D172.16 (អត្ថបទកាសែតទស្សនាវដ្តី Newsweek ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៥)[27] ជាដើម។

(ឃ) ទីបួន៖ មេធាវីការពារក្តី អៀង សារី បានលើកឡើងនូវការជំទាស់ជាថ្មីម្តងទៀត ស្តីពីភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ពាក់ព័ន្ធទៅនឹងកំណត់ត្រាភាគច្រើននៅស្រុកត្រាំកក់ និងចម្លើយសារភាពមួយនៅមន្ទីរ ស-២១៖ *"ឯកសារនេះមានសម្ភារៈដែលអាចត្រូវបានប្រឡាក់ប្រឡូសទៅដោយអំពើទារុណកម្ម។ ឯកសារដែលបានមកដោយការធ្វើទារុណកម្ម តាមទម្រង់ណាមួយក៏ដោយ និងនៅក្នុងកាលៈទេសៈណាក៏ដោយ (លើកលែងតែប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទទារុណកម្ម នៅពេលធ្វើចម្លើយនោះ គឺមិនអាចទទួលយកបាននៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ នៅចំពោះមុខ អ.វ.ត.ក ឡើយ។ គ្រប់ព័ត៌មានស្តីពីជីវប្រវត្តិដំបូងទាំងអស់ និងភ័ស្តុតាងដទៃទៀតដែលមាននៅក្នុងឯកសារនេះ ដែលបានមកដោយសារការធ្វើទារុណកម្ម [គឺ] មិនអាចទទួលយកបានឡើយ។ សម្ភារៈដែលបានមកដោយសារការធ្វើទារុណកម្ម តាមច្បាប់មិនត្រូវបានអនុញ្ញាតទេ ហើយមិនគួរឲ្យជឿជាក់បានទេ"* ។ ខៀវ សំផន ក៏បានអះអាងផងដែរថា ចម្លើយសារភាពលេខឯកសារ IS 5.63 របស់ **មូល សម្បត្តិ** ត្រូវបានមកដោយការធ្វើទារុណកម្ម និងរឹតតែមិនពាក់ព័ន្ធទៀត។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានច្រានចោលការជំទាស់បែបដូច្នេះជាច្រើនដងរួចមកហើយ ដោយអនុញ្ញាតឲ្យមានការប្រើប្រាស់ភ័ស្តុតាងមានកម្រិតដែលបានមកដោយសារការធ្វើទារុណកម្ម[28] និងដោយការទទួលយកឯកសារមន្ទីរស-២១ និងកំណត់ត្រាស្រុកត្រាំកក់ទាំងអស់ ដែលបានស្នើសុំពីមុនដោយភាគីនានា[29]។ បន្ថែមលើនេះ មេធាវីការពារក្តីមិនបានបង្ហាញអង្គហេតុពិតដែលថា អំពើ

---

[26] **E223/2/2.5**, លេខ ៥។

[27] **E223/2/2.5**, លេខ ៧។

[28] **E185**, កថាខណ្ឌទី ២១.៩។ **E185/1**, សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14 –A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត, ៣ ធ្នូ ២០១២, កថាខណ្ឌទី ១៧។

[29] **E185/1**, សេចក្តីសម្រេច។

ទារុណកម្ម ត្រូវបានប្រើប្រាស់ដើម្បីបង្កើតឯកសារដែលឯកសារនោះត្រូវបានជំទាស់។ ឯកសារស្រុកត្រាំកក់មានចុះជាបញ្ជីនៅក្នុងឯកសារលេខ E223/2/1.2 ដែលមានបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានធ្វើការប្រាស្រ័យទាក់ទងគ្នា ដោយមន្ទីរសន្តិសុខក្រាំងតាចាន់ផ្ញើជូនទៅថ្នាក់លើ, កំណត់ដៃអ្នកសួរចម្លើយរបស់មន្ទីរសន្តិសុខ ឬបញ្ជីឈ្មោះខ្មាំង ឬពួកសង្ស័យ ដែលត្រូវបានបញ្ជូនដោយថ្នាក់ឃុំ ទៅកាន់ស្រុក១០៥។ របាយការណ៍ទាំងនោះដែលត្រូវបានផ្ញើដោយមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ទៅកាន់អាជ្ញាធររដ្ឋបាលថ្នាក់លើ មិនមែនជាឯកសារដែលបានមកដោយសារការធ្វើទារុណកម្មនោះឡើយ។ ដូចដែលបានលើកឡើងជាច្រើនដង នៅក្នុងអង្គជំនុំជម្រះដូច្នោះដែរ សហព្រះរាជអាជ្ញាមិនធ្លាប់ដែលបានប្រើទាល់តែសោះនូវចម្លើយសារភាព ដែលបានមកដោយការធ្វើទារុណកម្ម មកធ្វើជាបរិបទរបស់ខ្លួនឡើយ។ យ៉ាងណាក៏ដោយ ចំណារ និងរបាយការណ៍នានារបស់អ្នកសួរចម្លើយ, ព័ត៌មានជីវប្រវត្តិដែលបានមកនៅមុនពេលធ្វើទារុណកម្ម អាចនឹងត្រូវបានប្រើប្រាស់ដោយស្របច្បាប់ ស្របទៅនឹងទារុណកម្មដែលអនុញ្ញាត ដោយអនុសញ្ញាអន្តរជាតិស្តីពីអំពើទារុណកម្ម។ រីឯភាពទាក់ទងនៃចម្លើយសារភាពលេខឯកសារ IS 5.63 ដែលបានប្រឆាំងដោយ ខៀវ សំផន ឯកសារដែលមានការទាក់ទងនេះគឺ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ, គោលនយោបាយបោសសម្អាតខ្មាំង ក៏ដូចជា រចនាសម្ព័ន្ធរដ្ឋបាលនៃកម្ពុជាប្រជាធិបតេយ្យដែរ (មុខតំណែងរបស់ រស់ ញឹម ក្នុងឋានៈជាលេខាភូមិភាគពាយ័ព្យ)។ លើសពីនេះ ឯកសារសហកាលសម័យកម្ពុជាប្រជាធិបតេយ្យដែលមានប្រភពមកពី DC-Cam ឯកសារទាំងនេះ ដោយយោងទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឯកសារលេខE185 "ជាឯកសាររងការជំទាស់អំពីភាពពាក់ព័ន្ធមួយក្រឡេកភ្នែក និងភាពជឿជាក់បាននៃឯកសារនោះ (រួមទាំងយថាភូតរបស់ឯកសារផង)"[30]។

(ង) ទីប្រាំ៖ មេធាវីការពារក្តី អៀង សារី បានលើកឡើងច្រំដែលនូវអំណះអំណាងពីមុនពាក់ព័ន្ធនឹងភាពលំអៀង ឬភាពទាគតិរបស់ DC-Cam ដែលបានចោទប្រកាន់ ហើយចោទថាអង្គការនេះ *"មិនដើម្បីស្វែងរកការពិតទេ {...} ប៉ុន្តែដើម្បីបញ្ជាក់ពីសេចក្តីសន្និដ្ឋាន*

---

[30] **E185**, កថាខណ្ឌទី ២៨។

*ដែលបានកំណត់មកពីមុនថាឧក្រិដ្ឋកម្មទាំងនេះបានកើតឡើង"*[31]។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងពីបញ្ហានៃភាពជឿជាក់ និងពីភាពលំអៀងដែលបានចោទប្រកាន់របស់ DC-Cam នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ឯកសារលេខ E185, ត្រង់កថាខណ្ឌទី២៥-២៨, ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ បន្ទាប់ពីសក្ខីកម្ម កាលពីថ្ងៃទី២៣-២៤ ខែមករា ឆ្នាំ២០១២ របស់លោកនាយករង Vanthan Dara អនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកនាយក Youk Chhang ជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១-២ ខែកុម្ភៈ ឆ្នាំ២០១២។

(ច) ទីប្រាំមួយ៖ មេធាវីការពារក្តីរបស់ អៀង សារី បានអះអាងថា ឯកសារចំនួន២០(ម្ភៃ) ដែលបានលើកឡើងនៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធាកម្ពុជាប្រជាធិបតេយ្យ គឺ *"ដាក់កាលបរិច្ឆេទនៃបញ្ហានោះឲ្យបានមុន នៅក្នុងសំណុំរឿង០០២/០១ និង {គឺ} មិនពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីទេ"*។ ដូចដែលបានទទួលស្គាល់ដោយមេធាវីការពារក្តី *"អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ខ្លួនធ្លាប់បានទទួលយកចំពោះភស្តុតាងដែលពុំស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នៅពេលភស្តុតាងទាំងនោះមានភាពពាក់ព័ន្ធ ក្នុងការបញ្ជាក់អំពីព័ត៌មាន ឬបរិបទសារតារ។ សូមអានឯកសារលេខ E185, កថាខណ្ឌទី ២៩"*។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថាមេធាវីការពារក្តីខកខានមិនបានបង្ហាញថាឯកសារនីមួយៗក្នុងចំណោមឯកសារពាក់ព័ន្ធទាំង២០(ម្ភៃ)នោះ គឺ "មិនពាក់ព័ន្ធ និងមិនច្រំដែល" ដូចដែលមេធាវីបានបញ្ជាក់នៅក្នុងការជំទាស់របស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ឯកសារទាំងនោះ ដូចជាឯកសារលេខ D172.21, D178.11 ឬ D248/5.1.28 គឺសុទ្ធតែពាក់ព័ន្ធ ដោយហេតុថាឯកសារនោះ បានរាយការណ៍អំពីលក្ខខណ្ឌនៃការរស់នៅក្នុងទីក្រុងភ្នំពេញ នាសម័យសាធារណរដ្ឋខ្មែរ ឬនៅទីកន្លែងផ្សេងទៀតនៅក្នុងប្រទេស ហើយមានទំនោរក្នុងការបង្ហាញនូវស្ថានភាពពិតប្រាកដនៃអ្នកស្រុក និងជនភៀសខ្លួន នៅមុនពេលកាន់កាប់ និងជម្លៀសឲ្យចេញពីទីក្រុងភ្នំពេញ ដោយកងកម្លាំង FUNK ។

[31] **E223/2/2.3**, ឯកសារ ១ (IS 18.78)។ សូមអានផងដែរ E223/2/2.5, ឯកសារ ៤ (D125/97) កន្លែងដែលមេធាវីការពារក្តីបានថ្លែងថាពួកគាត់យល់ឃើញថា DC-Cam មានភាពលំអៀង។

(ឆ) ចុងបញ្ចប់ នៅក្នុងឧបសម្ព័ន្ធ ឯកសារលេខ E223/2/2.5 មេធាវីការពារក្តីរបស់ អៀង សារី ខកខានមិនបានលើកឡើងពីបញ្ហាសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពជឿទុកចិត្ត (រួមទាំង យថាភាព) ដោយដាក់ភ្ជាប់ទៅនឹងឯកសារទាំងអស់នោះ ដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើយុត្តិកម្មលើអត្ថិភាពនៃសច្ចធារណ៍នេះ តាំងពីយូរមកហើយ គឺតាំងពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ មកម្ល៉េះ ហើយធ្លាប់បាននិយាយពីបញ្ហានេះដដែលៗចាប់តាំងពីពេលនោះមក ទាំងនៅក្នុងសេចក្តីសម្រេច ឯកសារលេខ E185 និងឯកសារលេខ E185/1[32]។

(ខ) <u>អង្គជំនុំជម្រះសាលាដំបូង ពីមុនធ្លាប់បានទទួលយកឯកសារដែលបង្ហាញពីទិដ្ឋភាពខាងក្នុង និងខាងក្រៅ ចំពោះឯកសារដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន</u>

១០- នៅថ្ងៃទី៩ ខែមេសា និងថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចសំខាន់ៗចំនួន២(ពីរ) ដោយបានទទួលយកនូវឯកសារចំនួនរាប់ពាន់ ដែលបានស្នើឡើងដោយភាគីនានា រួមមានឯកសារទាំងអស់ លើកលែងតែឯកសារចំនួន១២(ដប់ពីរ) ដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ១-៥ នៃបញ្ជីឯកសាររបស់ ក.ស.ព ដែលបានពិនិត្យឡើងវិញ ស្របតាមវិធាន៨០ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ (ឯកសារលេខ E109/4) និងឯកសារទាំងអស់ដែលមិនមែនជាឯកសារថ្មី ដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ៦-១១ និង ១៤-២០ នៅក្នុងញត្តិតែមួយ ឯកសារលេខ E109/4 លើកលែងតែឯកសារចំនួន ៧(ប្រាំពីរ) ចេញ។

១១- សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា កាលណាប្រភេទនៃឯកសារដែលធ្លាប់ត្រូវបានពិចារណារួចហើយដោយអង្គជំនុំជម្រះសាលាដំបូង ថាជាឯកសារដែលអាចទទួលយកបាននោះ ឯកសារដទៃទៀតណា ដែលបានដាក់បង្ហាញដោយមានចរិកលក្ខណៈដូចគ្នា (ប្រភេទ, សន្ទស្សន៍ លើភាពជឿជាក់ ផ្នែកខាងក្នុង និងខាងក្រៅនៃឯកសារ រួមទាំង យថាភាព និងភាពពាក់ព័ន្ធ) គួរត្រូវបានទទួលយកធ្វើជាភ័ស្តុតាង ដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយស្របទៅនឹងច្បាប់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះដែលមានកន្លងមក។

---

[32] **E1/34.1**, ប្រតិចារឹកអង្គជំនុំជម្រះសាលាដំបូង, ២៦ មករា ២០១២, ១៥:០៥ ដល់ ១៥:១៧ ។ **E162**, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន, ៣១ មករា ២០១២, កថាខណ្ឌទី ៣។ **E185**, កថាខណ្ឌទី ២។ **E185/1**, កថាខណ្ឌទី ៩.ក។

១២- ចំណែកបញ្ជីឯកសារលេខ E223/2/1.1ដែលមានចំនួន៤៨ឯកសារ ដែលបានស្នើឡើងដោយភាគីផ្សេងៗគ្នាវិញ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី និង ខៀវ សំផន បានជំទាស់ទៅនឹងការទទួលយកនូវសៀវភៅមួយចំនួនតូច (ឯកសារលេខ E216/3.1 និងលេខ E152.2), ចម្លើយសារភាពមួយដែលស្រង់ដោយមន្ទីរស-២១(IS5.63), របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង (ឯកសារលេខD125/217) និងខ្សែវីដេអូចំនួនបួនខ្សែ (ឯកសារពីលេខ E152.1.1R ដល់លេខ E152.1.54R, E190.1.297R, E93/7.3R និងលេខ E93/7.2R, E186.1R)។ ឯកសារទាំងនេះបង្ហាញពីលក្ខណៈពិសេសដូចគ្នាបេះបិទទៅនឹងឯកសារជាច្រើនដែលនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឯកសារលេខ E185/1 បានទទួលយក ជាផ្នែកនៅក្នុងឧបសម្ព័ន្ធដូចខាងក្រោមនេះនៃឯកសារលេខ E109/4 ៖ ឧបសម្ព័ន្ធទី 10 (ចម្លើយសារភាពស្រង់ដោយមន្ទីរស-២១ ចំនួន៣២០), ឧបសម្ព័ន្ធទី14 (របាយការណ៍របស់ កសចស ស្តីពីការកំណត់អត្តសញ្ញាណទីតាំងចំនួន ២),[33] ឧបសម្ព័ន្ធទី16 (ឯកសារជាខ្សែអាត់សម្លេង និងវីដេអូចំនួនជាង ៣០០) ហើយនិងឧបសម្ព័ន្ធទី១៩(អត្ថបទនៃការសិក្សាស្រាវជ្រាវជាន់ខ្ពស់, របាយការណ៍វិភាគ និងសៀវភៅចំនួនជាង២០០)។

១៣- ចំពោះឯកសារបន្ថែមចំនួន៩៤ ដែលរាយឈ្មោះក្នុងបញ្ជី ដោយការិយាល័យសហព្រះរាជអាជ្ញា (កសព) នៅក្នុងឯកសារលេខ E223/2/1.2, E223/2/1.3 និងលេខ E223/2/1.4 ដែលទាក់ទងនឹងការជម្លៀសប្រជាជន (ដំណាក់កាលទី១ និងទី២) និងទួលពោធិ៍ជ្រៃ ក្រុមមេធាវីការពារក្តីមិនបានជំទាស់ទៅនឹងការចេញផ្សាយរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) ឯកសារលេខ D199/26.2.116 នោះទេ ក៏ប៉ុន្តែបានជំទាស់ដោយមានប្រសិទ្ធភាពទៅនឹងរាល់ឯកសារផ្សេងទៀតទាំងអស់ដែលនៅក្នុងសហសម័យនោះ ដែលរួមមាន ការប្រាស្រ័យទាក់ទងរបស់អន្តរជាតិចំនួន១៥ (ឯកសារផ្លូវការរបស់ប្រទេសបារាំង និងសហរដ្ឋអាមេរិច), របាយការណ៍របស់បណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិចំនួន ២១(ជាសំខាន់អត្ថបទផ្សេងៗដែលបានចេញផ្សាយនៅ សហរដ្ឋអាមេរិក), រូបថត៤ សន្លឹក, របាយការណ៍របស់ស្រុកត្រាំកក់ចំនួន៤៩ ក៏ដូចជារបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ កសចស ចំនួនបី ហើយនិងរបាយការណ៍វិភាគចំនួនមួយ។ ឯកសារមួយ

---

[33] ទោះបីជាក្រុមមេធាវីរបស់ជនជាប់ចោទ ខៀវ សំផន បានចោទប្រកាន់ថា នៅក្នុងរបាយការណ៍នេះជាសំខាន់មានសេចក្តីសង្ខេបចម្លើយសាក្សីមួយ (E223/2/4.1, ឯកសារលេខ២) នោះក៏ដោយក៏ពួកគេមិនអាចតវ៉ាថា មានលក្ខណៈច្រំដែលៗបានដែរ ព្រោះដោយសារតែនៅក្នុងនោះមានព័ត៌មានផ្សេងៗទៀតដែលមានតម្លៃ ដូចជារូបថត ការពិពណ៌នាអំពីទីតាំង, ការវាស់វែងដោយGPS និងទីតាំងនៃរណ្តៅកប់សពរួម។ ធាតុផ្សំទាំងនោះ បន្ថែមតម្លៃជាក់លាក់ទៅលើឯកសារ ព្រោះដោយសារតែអនុញ្ញាតឲ្យភាគីនានា មានអារម្មណ៍ស្រម័យឃើញរូបភាពនៃទីតាំងទួលពោធិ៍ជ្រៃ។

ចំនួនធំដែលបានស្នើឡើងដោយ កសព កាលពីមុនមក ដែលស្ថិតនៅក្នុងប្រភេទនេះ ត្រូវបានទទួលយកនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះឯកសារលេខ E185/1, ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១១ រួចហើយ។ឯកសារដែលត្រូវបានអង្គជំនុំជម្រះចាត់ទុកថា ត្រូវបានដាក់ជូនចំពោះមុខខ្លួននោះ គឺមានលក្ខណៈដូចគ្នាបេះបិទ(ទាក់ទងអំពីទម្រង់, ប្រភពដើម, កាលបរិច្ឆេទ, ពាក្យពេចន៍ដែលប្រើ ជាដើម។ល។ ដោយឯកសារដែលទាំងឡាយដែលក្នុងពេលនេះត្រូវបានក្រុមមេធាវីបដិសេធ។ អង្គជំនុំជម្រះបានទទួលយកនូវការប្រាស្រ័យទាក់ទងរបស់អន្តរជាតិចំនួនជាង១០០ (ពីឧបសម្ព័ន្ធទី១៧ ដល់ឯកសារលេខ E109/4), របាយការណ៍របស់បណ្តាញផ្សាយព័ត៌មានអន្តរជាតិចំនួនជាង៣០០ (ឧសម្ព័ន្ធទី១៨), កំណត់ហេតុរបស់ស្រុកត្រាំកក់ជាង៥០ (ឧបសម្ព័ន្ធទី៨) និងផែនទី និងរូបថតចំនួនជាង២០០ និងរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសចំនួនជាង១០០។ មិនមានហេតុផលជាអត្ថនោម័តណាមួយដែលធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូង ងាកចេញពីសេចក្តីសម្រេចកាលពីមុនរបស់ខ្លួន ហើយធ្វើការច្រានចោលនូវភាពអាចទទួលយកបាននៃឯកសារណាមួយដែលមានរាយឈ្មោះក្នុងបញ្ជីនៅក្នុងឯកសារលេខ E223/2/1.2, E223/2/1.3 និង E223/2/1.4 នោះឡើយ។

១៩- នៅចុងបញ្ចប់ ក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី បានជំទាស់ទៅនឹងឯកសារទាំងអស់ដែលបានលើកសំអាងនៅក្នុងលេខយោងជើងទំព័រនៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងរចនាសម្ព័ន្ធយោធាកម្ពុជាប្រជាធិបតេយ្យថាដែលថាឯកសារនោះត្រូវបើកចំហរដើម្បីធ្វើការពិភាក្សា។ ិសម្រាប់ភាគច្រើនជាងគេបំផុត ឯកសារទាំងនោះអាចត្រូវបានធ្វើចំណាត់ថ្នាក់នៅក្នុងប្រភេទដូចគ្នាដែលដូចដែលបានបញ្ជាក់ពីខាងលើស្រាប់ ហើយដែលកាលពីមុនត្រូវ បានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះ ដែលហេតុដូចនេះគួរតែត្រូវបានទទួលយក។

### គ. <u>សេចក្តីសង្កេតបន្ថែមលើការជំទាស់របស់ អៀង សារី និងខៀវ សំផន</u>

១៥- ការជំទាស់មួយចំនួនតូចដែលបញ្ជូនមកដោយក្រុមមេធាវីការពារក្តីនានា ចាំបាច់ត្រូវតែលើកឡើងដាច់ដោយឡែកពីគ្នា ចំពោះការលើកសំអាងផ្សេងៗដែលមាននៅក្នុងផ្នែក (ក) និង (ខ) និងបន្ថែមពីលើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ដែលបានរៀបរាប់លម្អិត នៅក្នុងសវនាការកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣។

១៦- ទាំងពីរក្រុមបានជំទាស់ទៅនឹងរបាយការណ៍របស់វិទ្យុ BBC SWB ដែលមានចំណងជើងថា ៖ "ការថ្លែងសន្ទរកថារបស់ ប៉ុល ពត នៅក្នុងពិធីរំឭកថ្ងៃខួបរបស់បក្ស" ដែលបានលើកឡើងជាឯកសារយោងលេខ D366/7.1.302 នៅក្នុងឧបសម្ព័ន្ធទី២ "ក" របស់ កសព (ឯកសារលេខ E223/2/1.2)[34]។ នេះគឺជាផ្នែកដំបូងនៃសន្ទរកថា ដែលបានអានកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៨ ដោយ ប៉ុល ពត នៅឯអង្គមីទិញមហាជនមួយ ដែលវិទ្យុផ្សាយសម្លេងក្រុងភ្នំពេញបានផ្សាយកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៨។ អៀង សារី *បានជំទាស់នឹងឯកសារនេះថា៖ "លុះត្រាតែបង្ហាញភស្តុតាងឱ្យឃើញពីយថាភាព។ មិនគ្រាន់តែប្រតិចារិករបស់វិទ្យុ BBC តែប៉ុណ្ណោះ នោះទេ តែសុំឱ្យបង្ហាញពីខ្លឹមសារសន្ទរកថានោះផង។ គឺថា នោះគឺត្រូវបង្ហាញថាប្រតិចារិក ត្រូវដូចគ្នាគ្រប់ម៉ាត់ជាមួយនឹងសន្ទរកថាដែល ប៉ុល ពត បានថ្លែងជាក់ស្តែងនាពេលនោះ"*[35]។ ក្រុមមេធាវី ការពារជនជាប់ចោទ ខៀវ សំផន បានជជែកតវ៉ាថា ខ្លឹមសារនៃសន្ទរកថាមិនអាចយកមកធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងសន្ទរកថាដើមជាភាសាខ្មែរដែលមិនរកបាននោះទេ[36]។ សហព្រះរាជអាជ្ញា កន្លងមកធ្លាប់បានបង្ហាញភស្តុតាងនៅក្នុងសវនាការដេញដោលលើឯកសារ ផ្សេងទៀតថា ប្រតិចារិកទាំងរបស់សេវាកម្មផ្សាយព័ត៌មាន FBIS និងទាំងរបស់វិទ្យុ BBC SWB គឺសុទ្ធតែមានភាពស៊ីសង្វាក់គ្នាទៅវិញទៅមក ព្រោះដោយសារតែទីភ្នាក់ងារទាំងនេះបានស្តាប់និងធ្វើប្រតិចារិកនូវការផ្សាយ ក្នុងពេលតែមួយរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងករណីចំពោះមុខនេះ គឺមិនមែនមានតែសន្ទរកថារបស់ប៉ុលពតតែមួយដែលត្រូវបានធ្វើប្រតិចារិកនៅក្នុងឯកសាររបស់សេវាកម្មផ្សាយព័ត៌មាន FBIS ថ្ងៃទី២៩ ខែកញ្ញា និងថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៨ ដែលត្រូវបានទទួលយក នៅក្នុងសំណុំរឿងរួចហើយនោះទេ[37] ក៏ប៉ុន្តែទស្សនាវដ្តីទង់បដិវត្តដែលចេញផ្សាយក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ក៏បានធ្វើការចុះផ្សាយសន្ទរកថាដដែលនេះឡើងវិ

---

[34] ឯកសារលេខ **D366/7.1.302**, របាយការណ៍នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ ដែលមានចំណងជើងថា "គោលនយោបាយក្នុងស្រុក និងបរទេសរបស់កម្ពុជា: សន្ទរកថាថ្លែងដោយ ប៉ុល ពត ក្នុងឱកាសថ្ងៃបុណ្យរំឭកខួបកំណើតរបស់បក្ស " (វិទ្យុ BBC SWB), ចុះថ្ងៃទី២៩ កញ្ញា ១៩៧៨។

[35]ឯកសារលេខ **E223/2/2.1**, ការជំទាស់របស់ អៀង សារី , ត្រង់លេខ៣៦។

[36] ឯកសារលេខ **E223/2/4.2**, ការជំទាស់របស់ ខៀវ សំផន , ត្រង់លេខ៣៦។

[37] ឯកសារលេខ **E3/76** និងលេខ **D262.45**, របាយការណ៍នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ លេខចេញផ្សាយសំរាប់ខែកញ្ញា ឆ្នាំ១៩៧៨ (FBIS), ជាភាសាអង់គ្លេសត្រង់លេខ ERN 00170446-55, និងឯកសារលេខ **E3/294** និងលេខ **D262.46**, របាយការណ៍នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ លេខចេញផ្សាយសំរាប់ខែតុលា ឆ្នាំ១៩៧៨ (FBIS), ជាភាសាអង់គ្លេស ត្រង់លេខ ERN 00170162-69។

ញូតាមច្បាប់ដើមទាំងស្រុងជាភាសាខ្មែរផងដែរ[38]។ ការយកប្រភពឯកសារចំនួនបីនៅក្នុងពេលស្រប គ្នាមកបង្ហាញរួមជាមួយគ្នាគឺ មិនធ្វើឲ្យមានការមន្ទិលសង្ស័យអ្វីទៀតអំពីយថាភាព និងភាពគួរឲ្យជឿ ទុកចិត្តបាននៃសន្ទរកថានោះឡើយ ហើយដូចនេះ ឯកសារលេខ D366/7.1.302 នេះ គួរតែត្រូវបាន ទទួលយក។

១៧- គឺជាការដែលគួរឲ្យកត់សំគាល់ដែរថា ក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា មិនបានជំទាស់ ទៅនឹងសៀវភៅ ឯកសារលេខ E152.2 ដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាត" ដែល តែងនិពន្ធដោយលោក ថេត សម្បត្តិ, លោក Gina Chon (ដែលទំនងជា នួនជា), ទៅនឹងខ្សែភាពយន្ត ឯកសារដែលមានចំណងជើងថា "សត្រូវរបស់ប្រជាជន"(ឯកសារលេខ E186.1R) ដែលនិពន្ធដោយ លោក ថេត សម្បត្តិ ដដែល (និងលោក Rob Lemkin), ឬទៅនឹងខ្សែវីដេអូរបស់ នួន ជា ឯកសារលេខ E93/7.3R និងលេខ E93/7.2R។ ផ្ទុយពី ក្រុមមេធាវីការពារក្ដីរបស់ នួន ជា ក្រុមមេ ធាវីការពារក្ដីរបស់អៀង សារី និង ខៀវ សំផន បានជជែកតវ៉ាថា អ្នកនិពន្ធនៃសៀវភៅ និងខ្សែវីដេអូទាំងនេះបានជ្រើសយកតែការដកស្រង់មួយចំនួនតូច នៃការធ្វើសម្ភាសន៍ជាមួយ នួន ជា ដែលមានរយៈពេលជាងរាប់រយ ឬរាប់ពាន់ម៉ោងតែប៉ុណ្ណោះ និងថា" *វិធីដំណើរការនៃការពិនិត្យ កែសម្រួលដើម្បីបោះពុម្ពផ្សាយត្រូវបានរៀបចំឡើង ដើម្បីជំរុញធ្វើឲ្យប្រសើរឡើងនូវចំណុចយល់ឃើញ ជាពិសេសណាមួយតែប៉ុណ្ណោះ*" ។ ហេតុដូចនេះ ក្រុមមេធាវីការពារក្ដីរបស់អៀង សារី និង ខៀវ សំផន បានស្នើសុំឲ្យបដិសេធចោលនូវសំភារៈឯកសារទាំងនោះ លុះត្រាតែបណ្ណសារទាំងមូលត្រូវបាន ដាក់បញ្ចូលនៅក្នុងសំណុំរឿង ដោយត្រូវធ្វើជាប្រតិចារិក និងបកប្រែ ឬឲ្យលោក ថេត សម្បត្តិ មកផ្ដល់សក្ខីកម្មនៅក្នុងតុលាការ។ មេធាវីការពារក្ដីរបស់ ខៀវ សំផន ថែមទាំងបានថ្លែងថា ខ្សែ ភាពយន្តឯកសារ និងកំណាត់ខ្សែភាពយន្តខ្លីៗចំនួន ១៦ខ្សែបន្ថែមទៀត គឺ"មិនមានភាពជាប់ទាក់ ទងគ្នាឡើយ"[39]។

១៨- សហព្រះរាជអាជ្ញាបានធ្វើការពន្យល់ដ៏វែងនៅក្នុងសវនាការកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ថា នួន ជា នៅក្នុងពេលសវនាការកាលពីថ្ងៃទី ១៤ ខែតុលាឆ្នាំ ២០១១ បានទទួលស្គាល់ថាខ្លួនបានជួបជា

---

[38] ឯកសារលេខ **E3/215** និងលេខ **D243/2.1.19**, ការចេញផ្សាយរបស់ បកក ដែលមានចំណងជើងថា "ទង់បដិវត្តន៍ " លេខចេញផ្សាយ លេខ៩, ចុះកាលបរិច្ឆេទ ខែកញ្ញា ឆ្នាំ១០៧៨។

[39] ឯកសារលេខ **E223/2/4.1**, ការជំទាស់របស់ ខៀវ សំផន , ក្រោមឯកសារលេខ៨។ ឯកសារលេខ **E223/2/2.4**, ការជំទាស់របស់ អៀង សារី, ក្រោមឯកសារលេខ៨។

មួយលោក ថេត សម្បត្តិ ហើយនិងបានធ្វើសម្ភាសន៍ជាមួយគាត់អស់ពេលជាច្រើនឆ្នាំទៀតផង និងបានប្រាប់ថាគាត់បានទុកចិត្តលោក ថេត សម្បត្តិ[40]។ សេចក្តីដកស្រង់បន្ថែមទៀតចេញពីខ្សែភាពយន្តឯកសារ មានលេខឯកសារ E186.1R ត្រូវបានបញ្ចាំងជូនដោយ CPLCL នៅក្នុងពេលសវនាការដេញដោលលើឯកសារកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២[41] ដោយមិនមានការជំទាស់ពីខាងមេធាវីការពារក្តីឡើយ។ រីឯសៀវភៅ ឯកសារលេខ E152.2 វិញ សហព្រះរាជអាជ្ញាបានយោងទៅលើសេចក្តីសន្និដ្ឋានដែលបានធ្វើឡើងនៅក្នុងញត្តិរបស់ខ្លួន ឯកសារលេខ E152 និងនៅក្នុងសវនាការកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ទាក់ទងទៅនឹងអង្គហេតុដែលថា នួន ជា បានថ្លែងថាគាត់បានសរសេរពីជីវប្រវត្តិផ្ទាល់ខ្លួនមួយរបស់គាត់ ហើបានឲ្យទៅលោក ថេត សម្បត្តិ ដើម្បីធ្វើការបោះពុម្ពផ្សាយ[42]។ ខ្សែវីដេអូ និងសៀវភៅដូចបានលើកឡើងខាងលើ គួរតែត្រូវបានទទួលយកធ្វើជាភ័ស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ផ្សេងដាច់ដោយឡែកពីសក្ខីកម្មណាមួយរបស់អ្នកនិពន្ធនៃខ្សែវីដេអូ និងសៀវភៅនេះ។ សំភារៈឯកសារទាំងនេះ គឺជាចម្លើយរបស់ នួន ជា ដែលមានជាប់ទាក់ទង គ្នា ខ្លាំងទៅនឹងប្រវត្តដើម តួនាទីរបស់ជនជាប់ចោទ គោលនយោបាយរបស់ បកកដែលក្នុងនោះរាប់បញ្ចូលទាំងការបោសសម្អាតខ្មាំងសត្រូវ រចនាសម្ព័ន្ធរដ្ឋបាល, ការប្រាស្រ័យទាក់ទង និងរចនាសម្ព័ន្ធយោធាផងនោះទេ។

១៩- ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ក៏ថែមទាំងបានធ្វើការជំទាស់ផងដែរទៅនឹងការទទួលយកឯកសារលេខ D108/31.28 ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ ដូចដែលបានរៀបរាប់នៅក្នុងបញ្ជីឯកសារលេខ E223/2/2.5 (លេខ.៣) របស់ អៀង សារី ។ គឺជាលិខិតមួយក្នុងចំណោមលិខិតជាច្រើនដែល (ស៊ូ) ម៉េតបានផ្ញើជូនទៅ ឌុច។ ខៀវ សំផន បានចោទប្រកាន់ថា ឯកសារនេះអាចឲ្យរកបានតែជាភាសាអង់គ្លេសប៉ុណ្ណោះ ហើយថា ដោយសារតែពុំមានឯកសារជាច្បាប់ដើមនោះ ឯកសារបកប្រែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) គឺមិនអាចឲ្យជឿទុកចិត្តបានឡើយ។ សហព្រះរាជអាជ្ញាបានជជែកតវ៉ា កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ថា តាមការពិតជាក់ស្តែង ឯកសារនេះគឺជាអត្ថបទផ្សេងមួយទៀតនៃការបកប្រែចេញពីច្បាប់ដើមជាភាសាខ្មែរ ឯកសារលេខ

---

[40] ឯកសារលេខ **E1/22.1**, ប្រតិចារិករបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៤ ធ្នូ ២០១១, ពីម៉ោង ១១ និង៤៥នាទី។

[41] ឯកសារលេខ **E1/134.1**, ប្រតិចារិករបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ តុលា ២០១២, ពីម៉ោង ១៥ និង១៩នាទី។

[42] ឯកសារលេខ **E152**, សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យទទួលយកនូវចម្លើយសក្ខីកម្មដែលពាក់ព័ន្ធ និងឯកសារនៃមន្ទីរស-២១ ដែលមានចំណារដែលប្រមូលបាននៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី១៩ សីហា ២០០៩។ ឯកសារលេខ **E1/161.1**, ប្រតិចារិករបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២១ មករា ២០១៣, ពីម៉ោង ១១និង៣៧ នាទី។

E3/1049 ឬលេខ D108/7.3 ទៅជាភាសាអង់គ្លេស និងថាមិនមានការចាំបាច់អ្វីត្រូវធ្វើការពិភាក្សាលើការបកប្រែនេះ ឯកសារលេខ D108/31.28 លើកជាសំអាងនៅក្នុងលេខយោងជើងទំព័រណាមួយនៃដីកាដំណោះស្រាយនោះទេ ឬឲ្យដែលអង្គជំនុំជម្រះសាលាដំបូងដឹងដើម្បីនឹងធ្វើការ សម្រេចមួយថ្មីទៀតលើឯកសារនេះ។ ក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី បានគូសបញ្ជាក់ខុសគ្នាបន្តិចនៅក្នុងឯកសារបកប្រែជាភាសាអង់គ្លេស ដែលចេញពីឯកសារជាភាសាខ្មែរតែមួយ ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្រឆាំងទៅនឹងសហព្រះរាជអាជ្ញាដែលថា គួរតែបើកចំហរដើម្បីធ្វើការពិភាក្សាប្រកបដោយប្រសិទ្ធភាព ប៉ុន្តែនៅក្នុងពេលទន្ទឹមគ្នានេះ គួរតែត្រូវបានបដិសេធ ព្រោះដោយសារមិនអាចឲ្យទទួលយកបាន។ ដោយសារតែ ឯកសារច្បាប់ដើមជាភាសាខ្មែរ (ឯកសារលេខ E3/1049) ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ រួចហើយនោះ ក្រុមមេធាវីការពារក្តីទាំងពីរក្រុមមិនចាំបាច់លើកឡើងនូវការជំទាស់ណាមួយ ស្តីពី ឯកសារបកប្រែជាភាសាអង់គ្លេសដែលមានពីរជាន់គ្នានេះឡើយ។

២០- នៅក្នុងឯកសារលេខ E223/2/4.2 ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន បានជំទាស់ទៅនឹងការប្រាស្រ័យទាក់ទងរបស់អន្តរជាតិ និងរបាយការណ៍របស់បណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិដូចដែលបានរៀបរាប់នៅក្នុងបញ្ជីឯកសាររបស់ កសព ចាប់ពីលេខ២ ដល់ លេខ៣៥ នៃឯកសារ E223/2/1.2 (ឧបសម្ព័ន្ធទី២ ក) ។ បន្ថែមពីលើ ការលើកសំអាងផ្សេងទៀតដែលបានលើកឡើងរួចខាងលើ ក្រុមមេធាវីការពារជនជាប់ចោទបានបញ្ជាក់ថា ឯកសារទាំងនោះ អាចមានភាពច្រំដែលពីព្រោះសាក្សីផ្សេងទៀត ជាជាងសាក្សីទាំងឡាយដែលរៀបរាប់អំពីព្រឹត្តការណ៍នានា នៅក្នុងឯកសារដែលនឹងត្រូវផ្តល់សក្ខីកម្មលើអង្គហេតុដដែលនេះ ហើយថា ក្រុមមេធាវីទាំនេះបានថ្លែងថាការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃភស្តុតាងដែលប្រហែលជាប្រសើរជាងគេបំផុត។ ក្រុមមេធាវីការពារក្តីក៏បានបញ្ជាក់ផងដែរថា ឯកសារជាច្រើនក្នុងចំណោមឯកសារទាំងនេះ គឺអាចនឹងមិនមានការទាក់ទងទេ ដោយសារនៅក្នុងឯកសារទាំងនេះបានលើកឡើងពិភាក្សាអំពីស្ថានភាពនៃជីវភាពរស់នៅ នៅស្ថានទូតបារាំងនៅក្នុងចន្លោះពេលពីថ្ងៃ១៧ ខែមេសា និងដើមខែ ឧសភា ឆ្នាំ១៩៧៥។ សហព្រះរាជអាជ្ញាមិនបានយល់ស្របជាមួយនឹងការលើកសម្អាងទាំងនេះ។

២១- ទីមួយៈ សូមបញ្ជាក់ថាមេធាវីការពារក្តី ខៀវ សំផន បានស្នើឯកសារមួយចំនួនដែលគេអាចធ្វើចំណាត់ថ្នាក់ស្រដៀងគ្នា ថាជាការប្រាស្រ័យទាក់ទងអន្តរជាតិ និងរបាយការណ៍សារព័ត៌មាន[43] និងថា

---

[43] សូមអានឧទាហរណ៍ដូចជា ឯកសារលេខ **E223/2/1.1**,ដែលមានលេខពី១៩ ,លេខចាប់ពី១៩-៣០, និងពី៣៥-៣៧។

មេធាវីការពារក្តីបានរារាំងមិនឲ្យពិចារណាចំពោះប្រភេទឯកសារទាំងនោះថា មានយថាភូត និងភាពជាប់ពាក់ព័ន្ធ។ ទីពីរ៖ ចំពោះភាពជាប់ពាក់ព័ន្ធ ឯកសារដែលបានស្នើដោយ កសព សុទ្ធតែជាឯកសារដែលមានក្នុងពេលស្របាលគ្នា ដែលភាគច្រើនបានសរសេរឡើងក្នុងពេលមានការជម្លៀសទីក្រុងភ្នំពេញ ឬភ្លាមៗបន្ទាប់ពីនោះ ក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៧៥ និងមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការជម្លៀសប្រជាជនទីក្រុងភ្នំពេញ ការចាប់ខ្លួនមន្ត្រីសាធារណរដ្ឋខ្មែរនៅស្ថានទូតបារាំង ស្ថានភាពនៃការបោសសម្អាតទីក្រុងភ្នំពេញ ឬលក្ខខណ្ឌរស់នៅក្នុងស្ថានទូតបារាំង និងស្ថានភាពដែលបានសង្កេតទៅលើការធ្វើដំណើររបស់ជនបរទេសទៅកាន់ប៉ោយប៉ែត។ ឯកសារទាំងនោះមិនមានភាពច្រំដែលទេ ប៉ុន្តែជាការបង្រួបបង្រួមនិងពង្រឹងដល់ភាពជឿជាក់នៃសក្ខីកម្មរបស់សាក្សី ដែលបានធ្វើសវនាការរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ ឬដែលនឹងត្រូវធ្វើសវនាការនៅថ្ងៃខាងមុខ។ ក្រៅពីសក្ខីកម្មផ្ទាល់មាត់ ឯកសារសហកាលក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គឺមានសារៈសំខាន់ស្មើគ្នាដើម្បីដាក់បន្ទុកដែលជាការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញា។ ភ័ស្តុតាងជាឯកសារ និងជាសក្ខីកម្ម គឺត្រូវបានចងបំពេញបង្គ្រប់ឲ្យគ្នា មិនមែនមានលក្ខណៈដាច់មុខទៅវិញទៅមក ដូចដែលមេធាវីការពារក្តីបានលើកស្នើឡើងនោះទេ។ ជាឧទាហរណ៍ ឯកសារលេខ D199/26.2.194 គឺជាទូរលេខបារាំង ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ដែលបានពោលថា មនុស្សឈឺត្រូវបានគេដេញឲ្យចាកចេញពីមន្ទីរពេទ្យនានានៅទីក្រុង។ ការណ៍នេះមិនត្រឹមតែត្រូវបានបញ្ជាក់ ដោយទូរលេខចំនួន ២(ពីរ) ផ្សេងទៀត ពីពួកមន្ត្រីផ្លូវការបារាំង[44] ដែលបានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ២.ក (E223/2/1.2) ដូចគ្នា ឬដោយរបាយការណ៍មួយរបស់សហរដ្ឋអាមេរិក ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៥ (D313/1.2.65) ប៉ុណ្ណោះទេ ថែមទាំងបានបញ្ជាក់ដោយសាក្សីផ្សេងៗទៀត ដែលបានរកទីជម្រកនៅស្ថានទូតបារាំង (ដូចជា សាក្សី TCW-536 ជាដើម)[45] ឬដែលត្រូវបានគេជម្លៀសជាមួយនឹងប្រជាជន ឧទាហរណ៍ដូចជា គិលានុបដ្ឋាកយិកា មាស សារ៉ាន់ (Meas Saran) ទៀតផង[46]។

---

[44] ឯកសារលេខ **D199/26.2.205** ចុះថ្ងៃទី១៩ មេសា ១៩៧៥ (លេខរៀងទី៤នៅក្នុងបញ្ជី ឯកសារលេខ E223/2/1.2) និងឯកសារលេខ **D199/26.2.219** ចុះថ្ងៃទី ២១ មេសា ១៩៧៥ (លេខរៀងទី៨ នៅក្នុងបញ្ជី, ឯកសារលេខ E223/2/1.2)។

[45] ឯកសារលេខ **E3/370**, កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី [TCW-536] ដោយ កសចស, ជាភាសាបារាំង ត្រង់លេខ ERN 00282826 (ទំព័រ ៣), ភាសាអង់គ្លេសលេខ ERN 00333951 (ទំព័រ ៣), ភាសាខ្មែរលេខ ERN 00286606 (ទំព័រ ៦)។

[46] ឯកសារលេខ **E1/144.1**, ប្រតិចារិករបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៤ វិច្ឆិកា ២០១២, នៅត្រង់ចន្លោះពីម៉ោង ១៥ និង២៨នាទី ដល់ ម៉ោង ១៥និង៣៥នាទី។ ឯកសារលេខ **E1/145.1**, ប្រតិចារិករបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២២ វិច្ឆិកា ២០១២, ដែលចាប់ផ្តើមពីម៉ោង ១០និង២០នាទី។

## IV. សេចក្តីសន្និដ្ឋាន

២២- អាស្រ័យហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះមេត្តាធ្វើការបដិសេធលើការជំទាស់ទាំងអស់ដែលលើកឡើងដោយក្រុមមេធាវីការពារក្តីរបស់ អៀង សារី និងខៀវ សំផន ទៅនឹងភាពអាចទទួលយកបាននៃឯកសារទាំងឡាយ ដែលបានស្នើសុំដោយការិយាល័យសហព្រះរាជអាជ្ញា ឬមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងឧបសម្ព័ន្ធ ឯកសារលេខ E223/2/1.1 (ឯកសារពីលេខ ១ ដល់១១) ដែលបានស្នើសុំដោយការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងឧបសម្ព័ន្ធ ឯកសារលេខ E223/2/1.2, E223/2/1.3 និង E223/2/1.4 ហើយស្នើឲ្យទទួលយកឯកសារដែលនៅសល់ចំនួន ៣០ទៀត ដូចដែលបានលើកឡើងនៅក្នុងលេខយោងជើងទំព័រនៃកថាខណ្ឌមួយចំនួន នៅក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធឃោធា ដូចដែលបានរៀបរាប់នៅក្នុងបញ្ជី នៅក្នុងពេលសវនាការកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ដោយ អៀង សារី ហើយដែលត្រូវបានកែតម្រូវដោយសហព្រះរាជអាជ្ញា។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | [signature] |